# អហិរាជសូត្រ (ធម៌វិរូបក្ខេ)

## (បិដក អដ្ឋកថា ដីកា)

### បាលី-ប្រែ (បិដកខ្មែរភាគ ៤២)



ដកស្រង់រៀបរៀងដោយភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# សេចក្ដីផ្ដើម

សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បានរៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និងបដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនារបស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជានិស្សិត ក្នុងសៀវភៅនេះផងដែរ ។

ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹងឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ ល្អតលាស់ ដៀនលឿនប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។

សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិតសម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួបចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួបចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។

វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី០៦ ខែមេសាឆ្នាំ២០២៣

# អហិរាជសុត្តំ (បិដក)

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរោ ភិក្ខុ អហិនា ទដ្ឋោ កាលង្កតោ ហោតិ។ អថ ខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ; ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ “ឥធ, ភន្តេ, សាវត្ថិយំ អញ្ញតរោ ភិក្ខុ អហិនា ទដ្ឋោ កាលង្កតោ”តិ។

“ន ហិ នូន សោ, ភិក្ខវេ, ភិក្ខុ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិ។ សចេ ហិ សោ, ភិក្ខវេ, ភិក្ខុ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរេយ្យ, ន ហិ សោ, ភិក្ខវេ, ភិក្ខុ អហិនា ទដ្ឋោ កាលង្ករេយ្យ។

“កតមានិ ចត្តារិ? វិរូបក្ខំ អហិរាជកុលំ, ឯរាបថំ អហិរាជកុលំ, ឆព្យាបុត្តំ អហិរាជកុលំ, កណ្ហាគោតមកំ អហិរាជកុលំ។ ន ហិ នូន សោ, ភិក្ខវេ, ភិក្ខុ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិ។ សចេ ហិ សោ, ភិក្ខវេ, ភិក្ខុ ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរេយ្យ, ន ហិ សោ, ភិក្ខវេ, ភិក្ខុ អហិនា ទដ្ឋោ កាលង្ករេយ្យ។

“អនុជានាមិ, ភិក្ខវេ, ឥមានិ ចត្តារិ អហិរាជកុលានិ មេត្តេន ចិត្តេន ផរិតុំ អត្តគុត្តិយា អត្តរក្ខាយ អត្តបរិត្តាយា”តិ។

“វិរូបក្ខេហិ មេ មេត្តំ, មេត្តំ ឯរាបថេហិ មេ;
ឆព្យាបុត្តេហិ មេ មេត្តំ, មេត្តំ កណ្ហាគោតមកេហិ ច។

“អបាទកេហិ មេ មេត្តំ, មេត្តំ ទ្វិបាទកេហិ មេ;
ចតុប្បទេហិ មេ មេត្តំ, មេត្តំ ពហុប្បទេហិ មេ។

"មា មំ អបាទកោ ហឹសិ, មា មំ ហឹសិ ទ្វិបាទកោ ;
មា មំ ចតុប្បទោ ហឹសិ, មា មំ ហឹសិ ពហុប្បទោ ។
"សព្វេ សត្តា សព្វេ បាណា, សព្វេ ភូតា ច កេវលា;
សព្វេ ភទ្រានិ បស្សន្តុ, មា កញ្ចិ  បាបមាគមា។
"អប្បមាណោ ពុទ្ធោ, អប្បមាណោ ធម្មោ;
អប្បមាណោ សង្ឃោ, បមាណវន្តានិ សរីសបានិ ។
"អហិវិច្ឆិកា សតបទី, ឧណ្ណនាភី សរពូ មូសិកា;
កតា មេ រក្ខា កតា មេ បរិត្តា , បដិក្កមន្តុ ភូតានិ ;
សោហំ នមោ ភគវតោ, នមោ សត្តន្នំ សម្មាសម្ពុទ្ធាន"ន្តិ ។

សត្តមំ។

## អហិរាជសូត្រ ទី៧ (បិដក)

[៦៨] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។ សម័យនោះឯង ក្រុងសាវត្ថី មានភិក្ខុមួយរូប ត្រូវពស់ចឹក ធ្វើមរណកាលទៅ។ លំដាប់នោះ ភិក្ខុជាច្រើន ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងសាវត្ថីនេះ មានភិក្ខុមួយរូប ត្រូវពស់ចឹក ធ្វើ

មរណកាលទៅ។ ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែន ព្រោះថា ភិក្ខុនោះ មិនផ្សាយចិត្តមេត្តា ចំពោះត្រកូលស្តេចពស់ ទាំង៤ពួក ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ ផ្សាយចិត្តមេត្តា ចំពោះត្រកូលស្តេចពស់ ទាំង៤ពួក ម្នាលភិក្ខុទាំងឡាយ ពស់មិនគប្បីចឹកភិក្ខុនោះឲ្យស្លាប់ទៅទេ ។ ត្រកូលស្តេចពស់ ៤ ពួក ដូចម្តេចខ្លះ ។ គឺត្រកូលស្តេចពស់ ឈ្មោះ វិរូបក្ខៈ១ ត្រកូលស្តេចពស់ឈ្មោះ ឯរាបថៈ១ ត្រកូលស្តេចពស់ ឈ្មោះ ឆព្យាបុត្តៈ១ ត្រកូលស្តេចពស់ឈ្មោះ កណ្ហាគោតមកៈ១ ។ ម្នាលភិក្ខុទាំងឡាយ ពិតដូច្នោះមែន ព្រោះថា ភិក្ខុនោះ មិនផ្សាយចិត្តមេត្តា ចំពោះត្រកូលស្តេចពស់ ទាំង ៤ ពួកនេះ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ ផ្សាយចិត្តមេត្តា ចំពោះត្រកូលស្តេចពស់ទាំង ៤ ពួកនេះ ម្នាលភិក្ខុទាំងឡាយ ពស់មិនហ៊ានចឹកភិក្ខុនោះឲ្យស្លាប់ទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យផ្សាយចិត្តមេត្តា ចំពោះត្រកូលស្តេចពស់ ទាំង ៤ ពួកនេះ ដើម្បីគ្រប់គ្រងខ្លួន រក្សាខ្លួន ការពារខ្លួន ។

ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈទាំងឡាយផង ភាវៈជាមិត្រ របស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះឯរាបថៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះឆព្យាបុត្តៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងត្រកូលស្តេចពស់ ឈ្មោះកណ្ហាគោតមកៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វឥតជើងទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វមានជើងពីរទាំងឡាយផង ភាវៈជាមិត្រ របស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វជើង ៤ ទាំងឡាយផង ភាវៈជា មិត្ររបស់អាត្មាអញ (ចូរមាន) ជាមួយនឹងសត្វមានជើងច្រើនទាំងឡាយផង។ សត្វឥតជើង កុំបៀតបៀន អាត្មាអញ សត្វជើងពីរ កុំបៀតបៀន អាត្មាអញ សត្វជើង ៤ កុំបៀតបៀន អាត្មាអញ សត្វជើងច្រើន កុំ

បៀតបៀន អាត្មាអញ ឡើយ ។ សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នាសត្វទាំងអស់ (នោះ) ចូរប្រទះ នូវសេចក្តីចំរើនទាំងឡាយ សេចក្តីអាក្រក់បន្តិចបន្តួច កុំមកឡើយ ។

ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ កណ្តុរ សុទ្ធតែមានប្រមាណ (រាប់បាន) គឺថា មិនច្រើនដូចគុណព្រះរត្នត្រ័យទេ ។ កិរិយារក្សា ខ្ញុំបានធ្វើហើយ កិរិយាការពារ ខ្ញុំបានធ្វើហើយ ពួកសត្វចូរចៀសទៅ ខ្ញុំសូមនមស្ការ ចំពោះព្រះដ៏មានព្រះភាគ សូមនមស្ការព្រះសម្មាសម្ពុទ្ធ ទាំង ៧ ព្រះអង្គ ។

## ៧ .អហិរាជសុត្តវណ្ណនា (អដ្ឋកថា)

៦៧ .សត្តមេ ឥមានិ ចត្តារិ អហិរាជកុលានីតិ ឥទំ ទដ្ឋវិសានេវ សន្ធាយ វុត្តំ។ យេ ហិ កេចិ ទដ្ឋវិសា, សព្វេតេ ឥមេសំ ចតុន្នំ អហិរាជកុលានំ អព្ភន្តរគតាវ ហោន្តិ។ អត្តគុត្តិយាតិ អត្តនោ គុត្តត្ថាយ។ អត្តរក្ខាយាតិ អត្តនោ រក្ខណត្ថាយ។ អត្តបរិត្តាយាតិ អត្តនោ បរិត្តាណត្ថាយ។ បរិត្តំ នាម អនុជានាមីតិ អត្ថោ។

ឥទានិ យថា តំ បរិត្តំ កាតព្វំ, តំ ទស្សេន្តោ វិរូបក្ខេហិ មេតិអាទិមាហ។ តត្ថ វិរូបក្ខេហីតិ វិរូបក្ខនាគកុលេហិ។ សេសេសុបិ ឯសេវ នយោ។ អបាទកេហីតិ អបាទកសត្តេហិ។ សេសេសុបិ ឯសេវ នយោ។ សព្វេ សត្តាតិ ឥតោ បុព្វេ ឯត្តកេន ឋានេន ឱទិស្សកមេត្តំ កថេត្វា ឥទានិ អនោទិស្សកមេត្តំ កថេតុំ ឥទមារទ្ធំ។ តត្ថ សត្តា បាណា ភូតាតិ សព្វានេតានិ បុគ្គលវេវចនានេវ។ ភទ្រានិ បស្សន្តូតិ ភទ្រានិ អារម្មណានិ បស្សន្តុ។ មា កញ្ចិ បាប-

មាគមាតិ កញ្ចិ សត្តំ បាបកំ លាមកំ មា អាគច្ឆតុ។ អប្បមាណោ ពុទ្ធោតិ ឯត្ថ ពុទ្ធោតិ
ពុទ្ធគុណា វេទិតព្វា។ តេ ហិ អប្បមាណា នាម។ សេសបទទ្វយេបិ ឯសេវ នយោ។ បមា-
ណវន្តានីតិ គុណប្បមាណេន យុត្តានិ។ ឧណ្ណនាភីតិ លោមសនាភិកោ មក្កដកោ។ សរពូ-
តិ ឃរគោលិកា។ កតា មេ រក្ខា, កតា មេ បរិត្តាតិ មយា ឯត្តកស្ស ជនស្ស រក្ខា ច
បរិត្តាណញ្ច កតំ។ បដិក្កមន្តុ ភូតានីតិ សព្វេបិ មេ កតបរិត្តាណា សត្តា អបគច្ឆន្តុ, មា មំ
វិហេឋយឹសូតិ អត្ថោ។

# អដ្ឋកថា អហិសូត្រទី ៧

## “ផ្សាយមេត្តាចិត្តដល់ត្រកូលស្តេចពស់”

*គប្បីជ្រាបវិនិច្ឆ័យក្នុង អហិសូត្រទី ៧ ដូចតទៅនេះ ៖*

**[៦៨]** *បទថា* ***ឥមានិ ចត្តារិ អហិរាជកុលានិ*** *(ត្រកូលស្តេចពស់ទាំង ៤ នេះ) ត្រាស់សំដៅដល់ពិសដែលត្រូវពស់ទាំ ពិសដែលត្រូវពស់ទាំពួកណាមួយ ពិសទាំងអស់នោះ នៅក្នុងត្រកូលស្តេចពស់ទាំង ៤ នេះ ។ បទថា* ***អត្តគុត្តិយា*** *គឺ ដើម្បីឃុំគ្រងខ្លួន ។ បទថា* ***អត្តរក្ខាយ*** *គឺ ដើម្បីរក្សាខ្លួន ។ បទថា* ***អត្តបរិត្តាយ*** *គឺ ដើម្បីការពារខ្លួន ។ អធិប្បាយថា តថាគតទើបអនុញ្ញាតបរិត្តទុកដូច្នេះ ។*

*ឥឡូវនេះ ភិក្ខុគប្បីធ្វើបរិត្តនោះដោយវិធីណា កាលទ្រង់សម្តែងវិធីនោះ ទើបត្រាស់ថា* ***វិរូបក្ខេហិ មេ*** *(របស់យើង ចូរមានជាមួយពស់ត្រកូលវិរូបក្ខៈទាំងឡាយ) ជាដើម ។ ក្នុងបទទាំងនោះ បទថា* ***វិរូបក្ខេហិ*** *(ជាមួយពស់ត្រកូលវិរូបក្ខៈទាំងឡាយ) បានដល់ មានមេត្តាចិត្តជាមួយពស់ត្រកូលវិរូបក្ខៈទាំងឡាយ ។ សូម្បីក្នុងត្រកូលពស់ដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* ***អបាទកេហិ*** *បានដល់ ជាមួយសត្វមិនមានជើងទាំងឡាយ ។ សូម្បីក្នុងសត្វដ៏សេសក៏មានន័យនេះដូចគ្នា ។ សេចក្តីថា ជាដំបូង ទ្រង់ត្រាស់មេត្តា*

ចំពោះ ដោយហេតុៈប្រមាណប៉ុណ្ណោះហើយ ឥឡូវនេះ ទើបផ្ដើមបទថា **សព្វេ**
**សត្តា** (សត្វទាំងពួង) នេះ ដើម្បីត្រាស់មេត្តាមិនចំពោះ ។ ក្នុងបទទាំងនោះ
បទថា **សព្វេ បាណា** (សត្វដែលមានខ្យល់ដកដង្ហើមទាំងអស់) ទាំងអស់នេះ
ជាពាក្យពោលដល់បុគ្គលប៉ុណ្ណោះ ។ បទថា **ភទ្រានិ បស្សន្តុ** (ចូរប្រសព្វ
តែសេចក្ដីចម្រើន) សេចក្ដីថា ចូរឃើញតែអារម្មណ៍ដែលចម្រើនចិត្តចុះ ។
បទថា **មា កញ្ចិ បាបមាគមា** (កុំបានទទួលទោសដ៏លាមកអ្វីៗ ឡើយ)
សេចក្ដីថា វត្ថុដែលជាបាបដ៏លាមកកុំបានមកប្រសព្វក្នុងសត្វណាៗ ឡើយ ។
ក្នុងបទថា **អប្បមាណោ ពុទ្ធោ** (ព្រះពុទ្ធទ្រទ្រង់គុណរកប្រមាណមិនបាន)
នេះ គប្បីជ្រាប ពុទ្ធគុណថា **ពុទ្ធោ** ពិតណាស់ ពុទ្ធគុណទាំងនោះឈ្មោះថា
ហួសពីការប្រមាណ ។ សូម្បីក្នុងពីរបទដ៏សេស ក៏ន័យនេះឯង ។ បទថា
**បមាណវន្តានិ** (មានគុណល្មមប្រមាណ) បានដល់ ប្រកបហើយដោយប្រមាណ
នៃគុណ ។ បទថា **ឧណ្ណានាភី** បានដល់ ពីងពាងមានរោមត្រង់ពោះ ។
បទថា **សរពូ** បានដល់ តុកកែក្នុងផ្ទះ ។ បទថា **កតា មេ រក្ខា កតា មេ**
**បរិត្តា** (ការរក្សាយើងបានធ្វើហើយ ការការពារយើងបានធ្វើហើយ) សេចក្ដី
ថា ការរក្សា និងការការពារ ខ្ញុំបានធ្វើហើយ ដល់ជនប្រមាណប៉ុណ្ណោះ ។
បទថា **បដិក្កមន្តុ ភូតានិ** (សូមសត្វទាំងឡាយចូរចៀសចេញ) សេចក្ដីថា

សត្វទាំងឡាយសូម្បីទាំងអស់ ដែលខ្ញុំធ្វើការការពារហើយ ចូរចៀសចេញទៅ អធិប្បាយថា កុំបៀតបៀនខ្ញុំឡើយ ។

## ចប់អដ្ឋកថា អហិសូត្រទី ៧

### ៧ .អហិរាជសុត្តវណ្ណនា (ដីកា)

៦៧ .សត្តមេ ទដ្ឋវិសានេវាតិ អវធារណេន ទិដ្ឋវិសាទយោ និវត្តេតិ។ កដ្ឋមុខាទយោ ហិ ចត្តារោ អាសីវិសា ទដ្ឋវិសោ, ទិដ្ឋវិសោ, ផុដ្ឋវិសោ, វាតវិសោតិ បច្ចេកំ ចតុព្ពិធា ហោន្តីតិ វិសវេគវិការវសេន សោឡស វុត្តា។ តេសុ ទដ្ឋវិសានំ យេវ ឥធ គហណំ, ន ឥតរេសន្តិ ទស្សេតិ។ សេសំ សុវិញ្ញេយ្យមេវ។

អហិរាជសុត្តវណ្ណនា និដ្ឋិតា។

### ៧ .ការពណ៌នាអហិរាជសូត្រ (ដីកា)

ពាក្យថា ពិសពស់ដែលត្រូវពស់ខាំនោះឯង ក្នុងថ្ងៃទី ៧ មានសេចក្តីថា ពិសពស់ដែលត្រូវពស់ខាំជាដើម រមែងឲ្យប្រឡប់វិញ ព្រោះជាអវធារណសព្ទ ។ ក៏ពស់មាន ៤

ប្រភេទ មានពស់ កដ្ឋមុខ ជាដើម គឺ ទដ្ឋវិស១, ទិដ្ឋវិស១, ផុដ្ឋវិស១, វាតវិស១, គឺលោកពោលដោយចំណែក ១៦ ផ្សេងគ្នាដោយការចែកពស់មានពិសលឿនរហ័ស ។ បណ្ដាពស់ទាំងបួនប្រភេទនោះ ពស់ឈ្មោះទដ្ឋវិសប៉ុណ្ណោះជាការរាប់ក្នុងទីនេះ ក្រៅអំពីនេះ មិនជាការរាប់ក្នុងទីនេះទេ ។ន័យដ៏សេស គប្បីជ្រាបដោយល្អត្រឹមតែប៉ុណ្ណោះ ។